# ការសម្ភាសរបស់លោកអ៊ុំ ប៉ែន យិន

កៈ អ្នកសម្ភាសឈ្មោះ ញ៉េម សុគន្ធា ខៈ អ្នកត្រូវគេសម្ភាសឈ្មោះ ប៉ែន យិន

## <u>ការសង្ខេបរបស់លោកអ៊ុំ ប៉ែន យិន</u>

លោកអ៊ុំ ប៉ែន យិន នៅក្នុងប្រវត្តិគាត់គឺគាត់បានរៀបការ២ដង ប្រពន្ធ២ ហើយគាត់បានរៀបរាប់ពីពេលដែលគាត់ឆ្លងកាត់សង្គ្រាម ហើយគាត់បានឃើញពួក ប៉ុល ពត សម្លាប់មិត្តភក្តិរបស់គាត់នៅមុខគាត់ដោយចាប់បំបែកពួកគាត់ ហើយសម្លាប់ នៅនឹងស្រែក្រោយពីពួកគាត់ដកស្ទូងរួចនៅពេលយប់ ហើយការហូបចុក គឺមានការលំបាកយ៉ាងខ្លាំង។ អ៊ុំប្រុសគាត់ស្ដាប់មិនបានទេ តែគាត់ចេះអាន មូលហេតុដែលគាត់ស្ដាប់មិនបានមកពីគាត់ប្រើថ្នាំច្រើនពេក។

កៈ ជាដំបូងនាងខ្ញុំសូមថ្លែងអំណរគុណដល់អ៊ុំប្រុសដែលអោយខ្ញុំសម្ភាសអំពីជីវប្រវត្តិរបស់អ៊ុំ នាងខ្ញុំឈ្មោះ ញ៉េម សុគន្ធា ជាអ្នកសម្ភាសអំពីជីវប្រវត្តិរបស់អ៊ុំនៅក្នុងថ្ងៃនេះ។ ហើយថ្ងៃនេះគឺពួកយើងសម្ភាសគឺនៅក្នុងថ្ងៃទី០៤ ខែធ្នូ ឆ្នាំ២០១៧ ហើយការសម្ភាសមានទីតាំងនៅភូមិក្រពើហា៎ សង្កាត់ ព្រែកឬស្សី ក្រុងតាខ្មៅ ប្រទេសកម្ពុជា ខេត្តកណ្ដាល។ ហើយថ្ងៃនេះខ្ញុំនឹងសម្ភាសដល់អ៊ុំប្រុស អ៊ីចឹងអ៊ុំសូមប្រាប់ឈ្មោះ ពេញរបស់អ៊ំហា៎?

ខៈ ឈ្មោះ ប៉ែន យិន។

កៈ ចា៎ស! អាយុប៉ុន្មានហើយអ៊ុំ?

ខៈ អាយុ ក្នុងឆ្នាំនេះ៧៤បាទ។

កៈ ៧៤ឆ្នាំ អូខេ! អ៊ីចឹងដោយសារអ៊ុំរាងពិបាកនិយាយបន្តិច អ៊ីចឹងខ្ញុំឆ្លើយជំនួសគាត់នៅក្នុងសំបុត្រកំនើត អ៊ុំប្រុសឈ្មោះ ប៉ែន យិន កើតនៅថ្ងៃទី០៥ ខែមិថុនា ឆ្នាំ១៩៤៥។ នៅភូមិស្វៃក្រែង ឃុំធ្លក ស្រុក ស្វាយរៀង ខេត្តស្វាយរៀងប្រទេសកម្ពុជា។ ហើយគាត់មានម្ដាយឈ្មោះ មាស ផាត់ សញ្ជិតខ្មែរកើតឆ្នាំ១៩២៧ នៅភូមិស្វៃក្រែង ឃុំធ្លក ស្រុកស្វាយរៀង ខេត្តស្វាយរៀង ប្រទេសកម្ពុជា។ ហើយមានឪពុកឈ្មោះ ប៉ែន ផាន់ សញ្ជាតិខ្មែរកើតឆ្នាំ១៩២៤ នៅភូមិ

ស្វៃក្រែង ឃុំធ្លក ស្រុកស្វាយរៀង ខេត្តស្វាយរៀង ប្រទេសកម្ពុជា។ អ៊ីចឹងសព្វថ្ងៃ តើអ៊ុំមានបងប្អូនប៉ុន្មាននាក់?

ខ៖ មាន៩នាក់ តែស្លាប់បាត់បង់ទៅអត់គិតទេ គិតអ្នកនៅរស់សព្វថ្ងៃ។

ក៖ ៩នាក់ដែលនៅរស់។

ខ៖ អ្នកដែលស្លាប់ទៅ២នាក់ បាទស្លាប់តាំងពីនៅតូចៗ បាទ៣នាក់។

ក៖ ចាំស!

ខ៖ សព្វថ្ងៃនេះរួមរស់៩នៅដល់សព្វថ្ងៃ។

ក៖ ចាំស!

ខ៖ ខ្ញុំគាត់ស្លាប់ហើយស្លាប់៩ឆ្នាំហើយទៅបាទ។

ក៖ ចាំសអ៊ីចឹងតើអ៊ុំជាកូនទីប៉ុន្មាន?

ខ៖ ជាកូនទី២!

ក៖ ទី២!

ខ៖ បាទ! ខ្ញុំបាទទី១គាត់នៅសព្វថ្ងៃនេះបងស្រីខ្ញុំបាទ។

ក៖ ចាំស! ឥឡូវអ៊ុំហ្នឹអានសំនួរខ្លួនឯង។

ខ៖ តើបងប្អូនរបស់អ្នកមានឈ្មោះអ្វីខ្លះ? មួយ ឈ្មោះ ប៉ែន យួន ពីរ ខ្ញុំប៉ែន ឃិន បី ប៉ែន ឃឹម ស្រី។

ក៖ ចាំស!

ខ៖ តទៅប្អូនខ្ញុំស្រីឈ្មោះប្រុក បាទ។

ក៖ អ៊ីចឹងនឹងនិយាយពីសាច់រឿងរបស់អ៊ុំ។

ខ៖ តើអ្នកមីងចាំសាច់រឿងពីពួកគេដែរឬទេ? នៅចងចាំមាតុប្រទេស កើតសង្គ្រាមមួយជំនាន់ដែលបារាំងវាយសម្តេចសីហានុឡើងសោយរាជ្យ ខ្ញុំនឹងការសិក្សាបាក់បែក ស្រុកកើតសង្គ្រាមតម្រិះរាក់អ្នកអក្សរជ្រៅពេកក៏មើលមិនបានបាទ មើលបានមិនបានច្រើន មើលបានតិចកុំឱ្យតែអក្សរកាត់បើអក្សរដែលត្រង់ៗអាចមើលបានអត់អីទេ។ ក៖ ចាំស!

ខ៖ ក្រុមគ្រួសារខ្ញុំលំបាកណាស់គឺក្រតោកយាកក្នុងពេលស្រុកកើតសង្គ្រាម ខ្ញុំខ្លួនខ្ញុំការសិក្សាក៏បាក់បែកទៅ ណាឪពុកម្តាយខ្ញុំប្រកបមុខរបរផុតមុខផុតក្រោយ ខ្វះគ្រឿងសម្ភារៈ រកព្រឹកបានព្រឹករកល្ងាចបានល្ងាចពេលដែលមុនហ្នឹងគាត់ស្លាប់ទៅគឺគាត់ប្រកបដោយធ្វើស្រែនឹងធ្វើស្ករទឹកត្នោត ចំនែកខាងខ្ញុំងណោះរែកពន្ធលីសែងបាទ អស់ហើយប៉ុណ្ណឹងបាទ។

ក៖ អ៊ីចឹងអ៊ុំនឹងនិយាយពីឈ្មោះជីដូនជីតា។

ខ៖ ជីដូនជីតា! ជីតាខ្ញុំឈ្មោះមាស យាយផាត់ ម្តាយខ្ញុំឈ្មោះ មាស ផាត់ ឪពុកខ្ញុំឈ្មោះ ប៉ែន ផាន់។

ក៖ ចាស!

ខ៖ សព្វថ្ងៃនេះរបស់កម្មសិទ្ធិបាក់បែកទៅខ្ញុំទាមទារក្នុងខ្មែរក្រហម ខ្ញុំធ្វើឱ្យបាក់បែកទៅហើយឥឡូវក្នុងសង្គមនេះខ្ញុំអាចទាមទារកម្មសិទ្ធិមកឱ្យបងប្អូនខ្ញុំវិញប្រើប្រាស់។ បាទ ខ្ញុំទៅទាក់ទងមេភូមិ មេភូមិជួយឱ្យរបស់កម្មសិទ្ធខ្ញុំវិញពីដើមបានមកថៃវិញហើយ។

ក៖ អូខេ នេះអ៊ុំ!

ខ៖ តើអ្នកធ្លាប់ដឹងពីរឿងរបស់ពួកគាត់ដែរឬទេ?

ក៖ ពីជីដូនជីតា ហ្នឹងហើយ។

ខ៖ ជីដូនជីតាបាទ។ ជីដូនជីតាទាំងអស់ខ្ញុំធ្លាប់ដឹងបាទ ធ្លាប់ដឹងថាគាត់ជាអ្នកមានស្តុកស្តម្ភមួយ។ ខ្ញុំធំឡើងស្រុកកើតសង្គ្រាមផុតទៅខ្ញុំដឹងក្តីគឺគាត់មានហូបគ្រប់គ្រាន់បាទអ្នកមីង មាន គោមានក្របីប្រើប្រាស់ មានស្រូវដាក់នៅក្នុងជង្រុកនាពេលដែលខ្ញុំដឹងក្តីបាទដល់ពេលខ្ញុំធ្វើ ការបានមាំមួនខ្ញុំក៏ដុនដាបដោយសារជីដូនជីតាខ្ញុំគាត់ដឹកនាំធ្វើស្រែធ្វើចម្ការអត់ធ្វើទេ ធ្វើ សុទ្ធតែអ្នកស្នងដក ។

កៈ អ៊ុំអាចនិយាយថែមមកទៀតក៏បាន។

ខៈ ខ្ញុំចាំនៅគ្រាចងចាំបានប៉ុណ្ណឹងណាអ្នក។

កៈ អូខេ! និយាយពិអាពាហ៍ពិពាហ៍របស់អ៊ុំវិញម្ដង។

ខៈ អាពាហ៍ពិពាហ៍ ភរិយារបស់អ្នកមានឈ្មោះអ្វី?

ខៈ ភរិយារបស់ខ្ញុំហ្នឹងហេ៎?

កៈ ចា៎ស!

ខៈ ផ្ទាល់ខ្លួនរបស់ខ្ញុំ!

កៈ ចា៎ស !

ខៈ គាត់ស្លាប់ហើយប្រពន្ធរបស់ខ្ញុំបាទ ប្រពន្ធខ្ញុំនេះគឺខ្ញុំបានក្រោយបាទ ប្រពន្ធខ្ញុំស្លាប់ឈ្មោះឈ្មោះស្អីទេខ្ញុំភ្លេច ឈ្មោះ ឈឹម ឈុំ។

កៈ ចា៎ស! អ៊ីចឹងអ៊ុំមានប្រពន្ធ២ហេ៎?

(អ្នកនៅជាមួយអ៊ុំ)ៈ គាត់មាប្រពន្ធ២។

ខៈ ម្ដាយក្មេករបស់ខ្ញុំគាត់ឈ្មោះម៉ែន ម៉ាក់។

កៈ ម៉ែន ម៉ាក់។

ខៈ ឈ្មោះ ម៉ន សែម ប្រពន្ធសព្វថ្ងៃនេះ ខ្ញុំខំតស៊ូណាស់ សព្វថ្ងៃតាំងជារបស់ព្រះ។

កៈ ចា៎ស!

ខៈ ព្រះថាបើបានហើយមិនឱ្យបោះបង់ចោលឱ្យខំតស៊ូអស់កល្បអស់កាល។

កៈ ចា៎ស!

ខៈ បានម្ល៉ោះហើយខ្ញុំខំតស៊ូ ខ្ញុំអត់ទៅលួចទៅជួបកូនចៅខ្ញុំ សព្វថ្ងៃកូនខ្ញុំនេះនៅបាត់ដំបងបាទ។

កៈ ចាស! អ៊ីចឹងអ៊ុំរៀបអាពាហ៍ពិពាហ៍នៅពេលណា?

ខៈ តើអ្នករៀបអាពាហ៍ពិពាហ៍នៅពេលណា? នៅក្នុងឆ្នាំ១៩៦៦ បាទ។

កៈ ហើយប្រពន្ធក្រោយ?

ខៈ ប្រពន្ធក្រោយ!

កៈ ឆ្នាំណា?

ខៈ ប្រពន្ធក្រោយខ្ញុំរៀបចំតាំងពីឆ្នាំក្នុង៩២ (១៩៩២)។

កៈ ១៩៩២ ចាស!

ខៈ បានប្រពន្ធក្រោយនេះ។

កៈ អូខេ! អ៊ីចឹងអ៊ុំហ្នឹងនិយាយពីប្រវត្តិស្នេហារបស់អ៊ុំ។

ខៈ សម្រាប់ប្រពន្ធទីមួយខ្ញុំបានរៀបចំក្នុងឆ្នាំ១៩៦៦ ប្រពន្ធទី២ខ្ញុំរៀបចំនៅក្នុងឆ្នាំ៩២ (១៩៩២)។ បាទ! សព្វថ្ងៃខំតស៊ូ និង ខំរៀបចំទុកដាក់ក្រុមគ្រួសារក្រោយនេះទៅតាមបញ្ញត្តិរបស់ព្រះ អ្នកខ្ញុំធ្វើសេចក្តីទន់ទាបនៅក្នុងគ្រួសារសព្វថ្ងៃនេះ។ បាទ! មិនហ៊ានធ្វើអំពើកោងកាចអ្វីទេអត់ហ៊ានទេ គឺគោរពបញ្ញត្តិរបស់ព្រះឱ្យអស់ពីដួងចិត្តខ្ញុំ។

កៈ អូខេ! តើអ៊ុំជួបប្រពន្ធនៅពេលណា?

ខៈ ជួបប្រពន្ធក្រោយនៅពេលណាប្រពន្ធក្រោយនេះ?

កៈ ទាំង២?

ខៈ ទាំង២ បាទ។

កៈ ប្រវត្តិ ប្រវត្តិរបស់អ៊ុំហាំ? ប្រវត្តិអាពាហ៍ពិពាហ៍។

ខៈ បាទៗ! ទីមួយខ្ញុំរៀបចំនៅក្នុងឆ្នាំ១៩៦៦។

កៈ ហើយម៉េចដែរ?

ខ៖ គេក្រោយរៀបចំនៅក្នុងឆ្នាំ៩២(១៩៩២) រហូតមកទល់សព្វថ្ងៃនេះហើយ។

ក៖ អ៊ីចឹងដោយសារអ៊ុំនេះ គាត់ស្តាប់អ៊ុំសួរអត់បានដល់គាត់អានបានគាត់នេះ គាត់អាចយល់។ ឥឡូវនិយាយពីថ្លៃជំនូន។

ខ៖ តើមានថ្លៃជំនូនដែរឬទេ? ថ្លៃជំនូនស្អីគេអ្នកខ្ញុំអត់ទាន់យល់?

ក៖ តើអ៊ុំមានថ្លៃបណ្តាការដែរឬទេ?

ខ៖ ប្រែមកថាបណ្តាការ។

ក៖ បណ្តាការឱ្យទៅប្រពន្ធហាំ? ឱ្យទៅប្រពន្ធឱ្យទៅភរិយា។

(អ៊ុំមិនយល់ពីសំនួរ)

ក៖ អ៊ីចឹងអ៊ុំប្រាប់ពីសង្គម ប៉ុល ពត។

ខ៖ បាទ! ក្នុងសង្គមប៉ុល ពត ខ្ញុំបានភ្លួររស់កាប់គាស់តាមរដ្ឋក្នុងសង្គម ប៉ុល ពត នោះដឹកនាំធ្វើការទាំងយប់ទាំងថ្ងៃរួចទៅខ្ញុំទទួលទានដោយបបរ និង លាយត្រកួន អើខ្ញុំក៏មានការឈឺចិត្តខ្លាំងពេកក៏ធ្វើឱ្យបាក់បែកទ្រព្យសម្បត្តិខ្មែរក្រហមដូចជាខ្ញុំខំភ្លួររ៉ាស់ ទឹកត្រឹមភ្លៅនេះ ទៅមកហូបបបរ ទឹកមានការឈឺចិត្តខ្លាំងខ្ញុំបោកចានចោល ដឹងដល់ប្រធាន ប្រធានដឹងផ្លាស់ខ្ញុំមកសហករណ៍ធំខ្ញុំក៏បានផ្ទះត្រឹមត្រូវដល់ពេលមកផ្ទះសហករណ៍ធំនេះកម្មាភិបាលដាក់ខ្ញុំឱ្យបានផ្ទះនៅត្រឹមត្រូវ ផ្ទះក្បឿងនៅក្នុងក្រុមគ្រួសារខ្ញុំដែលគ្រួសារមុន គ្រួសារមុនខ្ញុំកម្មាភិបាលឱ្យដេរប៉ះខោអាវប្រជាពលរដ្ឋទាំងអស់
ចំនែកខ្លួនខ្ញុំឱ្យកម្មាភិបាលឱ្យមើលឱ្យថៃក្នុងរោងបាយឱ្យមើលឱ្យបងប្អូនឱ្យហូបឱ្យឆ្អែតពេលនោះខ្ញុំបាក់បែកចេញមកចូលក្នុងសហករណ៍ធំនេះ។ ខ្ញុំ បានហូបបាយសុទ្ធតែបាយគ្មានបបរទេ
បាទហើយទៅកម្មាភិបាលដាក់មុខងារខ្ញុំឱ្យចូលទៅមើលនៅក្នុងម៉ាស៊ីនកិនស្រូវ
ចំនួនមួយខែក៏ឈប់ទៅ ខ្ញុំមកមើលខាង រោងបាយកាន់កូនសោរនឹងរបស់របរមាសពេជ្រកងកែរដែលគេឱ្យដាក់រួម។ បាទ! តែនៅក្នុងឃ្លាំងហ្នឹងមានតែខ្ញុំ បាទ អស់ហើយបាទ។

ក៖ អូខេ! អ៊ីចឹងអ៊ុំចាំបានតែប៉ុណ្ណឹង។

ខៈ  នៅក្នុងសង្គមនោះខ្ញុំមើលក្នុងរោងបាយខ្ញុំខំយកចិត្តទុកដាក់មើលឱ្យបងប្អូនហូប  ឱ្យឆ្អែត អ្នកមិនឱ្យហូបបបរទេហូបបាយបាទមានបាយឱ្យហូប ហូប គឺត្រឹមត្រូវ។

កៈ អូខេ! អ៊ីចឹងអ៊ុំរស់នៅខេត្តណាពេលជំនាន់ប៉ុលពត? អ៊ុំនឹងអានសំនួរ។

ខៈ អ៊ុំរស់នៅក្នុងខេត្តណាពេលប៉ុល ពត? អើ! ក្នុងខេត្ត ក្នុងខ្មែរក្រហម ពីដើមពីសង្គមហៅថា ខេត្ត អើ ខេត្តបាត់ដំបង។ ឥឡូវនេះខ្ញុំរួមរស់ ហាក្នុងពេលនោះខ្ញុំរួមរស់នៅក្នុងសង្គម ប៉ុល ពត រួមរស់នៅក្នុងខេត្តបន្ទាយមានជ័យ។ បាទ! សព្វថ្ងៃនេះគេហៅខេត្តបន្ទាយមានជ័យ ស្វាយស៊ីសុផុនបាទៗ។

កៈ ហ្នឹងហើយ ដោយសារពេលមុនគេអត់ទាន់ ពេលមុនគេអត់ទាន់កាត់ជាបន្ទាយមានជ័យទេ គេហៅបាត់ដំបង។ ពេលមុនអត់មានបន្ទាយមានជ័យទេ មានតែបាត់ដំបងឥឡូវគេកាត់ជា២ចេញ ទៅជាបាត់ដំបងផង បន្ទាយមានជ័យផង។អូខេអ៊ំនឹងរៀបរាប់ពីជំនាន់ ប៉ុល ពតបន្ថែមទៀត។

ខៈ បាទ! ខ្ញុំជម្រាបអ្នករួចស្រេចអស់ហើយនៅក្នុងសង្គមប៉ុល ពតនេះ ភ្នូរាស់នឹងបបរខ្ញុំបានរៀបរាប់ជូនអ្នករួចស្រេចអស់ហើយ។

កៈ ចាស !

ខៈ អត់មានអ្វីទៀតទេ។

កៈ តែប៉ុណ្ណឹងទេហេ៎អ៊ុំហេ៎?

ខៈ ប៉ុន្តែដែលខ្ញុំវាយបែកបាក់បែក បោះចានចោលដល់ហើយប្រធានផ្លាស់មកគេសួរ ខ្ញុំគេសួរថាសូមនិយាយឱ្យអស់ពីខ្លួនឯង។ ខ្ញុំថាខ្លួនខ្ញុំគ្មានមុខរបរអីគេទេ មានតែទេស្រាស្រីល្បែង ខ្ញុំដោះស្រាយក្នុងជីវិតខ្ញុំ។    ខ្ញុំមិនហ៊ានថាធ្វើការអ្វីៗប៉ុន្តែខ្ញុំធ្វើការក្នុងចលនាសង្គមរាស្ត្រនិយមសម្រាប់អមសម្ដេចសីហនុ ថាខ្សែស្ដេច រួចទៅប្រពន្ធខ្ញុំដាស់តឿនថា ការឆ្លងដែនទៅគ្រប់ប្រទេសអ្នកថាប្រទេសណាក៏ខ្ញុំទៅបាន មកសង្គមខ្មែរក្រហមប្រពន្ធខ្ញុំរៀបរាប់ប្រាប់ខ្ញុំថា កាតនេះដុតចោលទៅបើទុកស្ដាយស្រណោះខ្មែរក្រហមឃើញគេវាយចោលក៏កើតនៅក្នុង សង្គមអមស្ដេច។ ម្ល៉ោះហើយខ្ញុំក៏ដោះស្រាយគេសួរខ្ញុំ គេសួរថាខ្ញុំថាមុខការអ្វី ខ្ញុំថាអត់មានមុខការមានតែស្រាស្រីល្បែង អ៊ីចឹងវិញខ្ញុំដោះស្រាយខ្លួនខ្ញុំ តែមិនមែនស្រាស្រីល្បែងទេ គឺខ្ញុំដោះ

ស្រាយជីវិតដោយខ្ញុំរក ដោះស្រាយថាធ្វើការរាជការខ្ញុំស្លាប់ហើយគេវាយចោលអ្នក វាយច្រើនចំពោះមុខខ្ញុំបាទ ។ ធ្លាប់ឃើញគេយកមនុស្សទៅសម្លាប់ទេ?

ក៖ អ៊ុំធ្លាប់ឃើញទេ?

ខ៖ បាទ! ពួកម៉ាកខ្ញុំអ្នកមានសក្តិ ពួកម៉ាកខ្ញុំសក្តិ៤ គេហៅទៅស្ទួងដកទាំងយប់ម៉ោង៧ វាកាចសាហាវ ចិត្តទាហានអ្នក ពេលហ្នឹងខ្ញុំស្តាប់អត់ឮពេលហ្នឹងឃោរឃៅទៅ លើគេពាក្យសម្តីគេនាំគ្នាហៅយកទៅស្ទួងយប់គេវ៉ៃចោលទាំងយប់បំរុង១២ស្ទួងហើយ ម៉ោង១២ចប់គេវាយកប់ហ្នឹងភ្លឺស្រែទឹកឡើងភក់ៗ។ បាទ! ខ្ញុំសូមជម្រាបជូនអ្នកតែប៉ុណ្ណឹងទេ (សំនួរ) តើអ្នក មានឃើញអ្នកណាគេស្លាប់ទៀតទេ? អត់ឃើញទេឃើញតែមួយពួកម៉ាកខ្ញុំរបស់ខ្ញុំ ប្រពន្ធវា សព្វថ្ងៃនៅសព្វថ្ងៃនៅកូនស្រី។ បើខ្ញុំបែកបាក់យូរហើយមិនដឹងស្លាប់រស់យ៉ាងណាទេ។តែនៅ តែប្រពន្ធពេលដែលគេសម្លាប់ប្តីចោលហ្នឹងប្រពន្ធនៅ មកនៅក្នុងសង្គមហ្នឹងក៏នៅ ឥឡូវ ខ្ញុំបាក់បែកតាំងពីវានៅខ្មែរក្រហមហ្នឹងមកលែងជួបវាទល់ឥឡូវនេះ នៅខាងវា វាស្លាប់ហើយ ពួកម៉ាកខ្ញុំសក្តិ៤ វាបានសម្តីកោងកាចទៅលើគេគេវាយអ្នក ជិត បានដើរមកផ្ទះហើយមិនដឹងយ៉ាងម៉េច ខ្ញុំឃើញចំពោះហ្នឹងដៃខ្ញុំតែម្តង ដើរជាមួយគ្នាគេ បំបែក ពីខ្ញុំទៅខ្ញុំឈរមើលគេវាយកប់ក្នុងភ្លឺស្រែ។

ក៖ អូយ!

ខ៖ កប់ទឹកអត់មានគោកទេទឹកភក់ៗនៅលើភ្លឺស្រែណោះ។

ក៖ អ៊ីចឹងមិត្តភក្តិអ៊ុំហ្នឹងគេយកទៅសម្លាប់ហ្នឹងគឺនៅមុខរបស់អ៊ុំម៉ងគឺទាញយកទៅសម្លាប់ នៅហ្នឹងតែម្តង។ អ៊ីចឹងអ៊ុំប្រាប់ជីវិតដែលពិបាកហាំ?

ខ៖ តើអ្នកអាចប្រាប់ខ្ញុំពីពេលដែលលំបាកក្នុងជីវិតរបស់អ្នកបានដែរឬទេ? បាន អត់អីទេអ្នក ខ្ញុំលំបាកនៅក្នុងសង្គមខ្មែរក្រហមអ្នក តោកយ៉ាកក្នុងសង្គមខ្មែរក្រហមឈឺ ឈឺអត់បានសម្រាកហើយហូបបបរសុទ្ធតែទឹក ហើយដល់ពេលខ្ញុំភ្នួររាស់ខ្ញុំធ្វើទាំងឈឺ បើហ៊ាន តែសម្រាកគេវាយខ្ញុំចោល សម្រាកអត់បានទៅទាំងឈឺទាំងយប់ ទាំងថ្ងៃមួយទៀតដូចយើងហៅថាមេឃុំ មេឃុំខ្មែរក្រហមមកឃើញខ្ញុំតោកយ៉ាកពេកគាត់ដឹកនាំខ្ញុំយកទៅមន្ទីរពេទ្យពេទ្យព្យាបាលខ្ញុំឱ្យរស់ទាល់តែសព្វថ្ងៃ ពេទ្យខ្មែរក្រហមបាទ ឃើញខ្ញុំតោកយ៉ាក ឃើញខ្ញុំជើងខ្ញុំហើមកម្ពស់នេះ ភ្នួរទឹកផងភក់ផង ហើមខ្លួចទាំងជើងហ្នឹងដើរក្តាប់ទៅហើយ ទៅក្តាប់ទៅជីវា

ចូលក្នុងក្រចកហ្នឹងហើមខូចជើងហ្នឹង ហើមកម្ពស់នេះ យកទៅពេទ្យយកទៅសម្រាក ពេទ្យ២ អាទិត្យបានជាពេទ្យខ្មែរក្រហម។ បាទ! ដូចយើងសព្វថ្ងៃហៅថាមេឃុំ គាត់មេឃុំខ្មែរក្រហម នោះហើយ ដឹកនាំខ្ញុំឱ្យទៅរស់បាទ។

ក៖ អូខេ! អ៊ីចឹងសំនួរបន្ទាប់ទៀត។

ខ៖ តើអ្នកមានបទពិសោធន៍ណាខ្លះដែលល្អៗក្នុងជីវិតរបស់អ្នក? បាទ! បទពិសោធន៍ខ្ញុំ ខ្ញុំមានគ្រួសារចិត្តខ្ញុំស្មោះត្រង់ចំពោះគ្រួសារទី១មកទី២ ខ្ញុំខំយកចិត្តទុកដាក់ក្នុងគ្រួសាររបស់ខ្ញុំមិនធ្វើអំពើក្បត់គឺយកចិត្តទុកដាក់ចំពោះកូនចៅឱ្យចេះដឹងឱ្យខំនៃនាំអោយចេះដឹងខំអប់រំបាទ។ បាទ! ទាំង២នេះ ទាំងប្រពន្ធទាំង២បាទ ។

ក៖ អូខេ! សំនួរបន្ទាប់ទៀត។

ខ៖ តើពេលដែលអ្នកនៅវ័យក្មេង តើអ្នកមានសង្ឃឹមចង់ធ្វើចង់ធ្វើអ្វីដែរ? ពេលដែលអ្នកធំឡើង? ហ្នំ! ខ្ញុំនៅក្នុងគ្រួសារឪម៉ែរបស់ខ្ញុំដុនដាបណាស់ អ្នក ខ្ញុំខ្វះខាតគ្រឿងចាន មានតែលីពន្ធសែងនឹងរែកឡើងត្នោត ធ្វើត្នោតធ្វើស្រែមើលឃ្វាលគោឃ្វាលក្របីនឹងបាចទឹក ស្រុកហ្នឹងក្របាចទឹកឆ្អែតបើមិនឆ្អែតទេក៏ហីទៅ ដុនដាបម៉ោង៩ម៉ោង១០យប់បានសម្រាក ថ្ងៃអ៊ីចឹងទៅស្ទូងដកហើយនិង ឃ្វាលគោហើយនិង ឃ្វាលក្របី ទុកដល់ល្ងាចឡើងទុកដាក់គោក្របីត្រឹមត្រូវ។ ខ្ញុំបានជញ្ជូនកន្តាប់ជញ្ជូនសំណាបទៅដាក់ស្រែភ្លឺឡើងស្ទូងទៀតអ្នក ម៉ោង៩យប់នៅងងឹត។ នេះប្រវត្តិរូបរបស់ខ្ញុំបាទដុនដាបងងឹតភ្លៀងតោកយ៉ាកអ៊ីចឹងនៅរែកគ្មានអ្វីទេ នៅរែកកណ្តាប់រែកកណ្តាប់យកទៅដាក់ស្រែ ស្រែភ្លឺឡើងម៉ោង៥ឡើងខ្ញុំក្រោកដុស ដុសលាងគោក្របី ភ្ជួររាសឱ្យបានដីស្ទូង។ បាទ! ម៉ោង៧ឡើងមានដីស្ទូង ហើយរហូតម៉ោង១១ថ្ងៃឈប់ហូបបាយហើយឃ្វាលគោទៀតឃ្វាលគោទៅម៉ោង៣។ ខ្ញុំទុកដាក់គោមួយឡែកសិនខ្ញុំដកសំណាបទុកសម្រាប់ស្ទូងបាទ អស់ហើយអ្នកតាមប្រវត្តិរូបបាទ។

ក៖ អូខេ! អ៊ីចឹងមួយទៀត។

ខ៖ បើសិន ជាអ្នកមានអ្វីមួយផ្តាំទៅប្រាប់កូនចៅជំនាន់ក្រោយៗ តើអ្នកនឹងប្រាប់អ្វីខ្លះ? ខ្ញុំចេះដឹងខ្ញុំអប់រំបងប្អូនរបស់ខ្ញុំ អ្នកមិនឱ្យលួចឆក់គេមិនឱ្យបោកប្រាស់គេ នៅល្អណាស់ សព្វថ្ងៃនេះនៅគ្រាដែលវាចងចាំខ្ញុំ។ បាទ មិនហ៊ានធ្វើអំពីអ្វីទៅលើគេទេអត់ឱ្យលួចប្លន់គេទេអ្នកសព្វថ្ងៃមិនឱ្យជំពាក់គេទេ។ បើជំពាក់គេសងគេឱ្យគ្រប់ សព្វប្អូនខ្ញុំដែលនៅរស់ សព្វថ្ងៃខ្ញុំបែកមកនៅណេះ ខ្ញុំបានដាស់តឿនលើវា វាយកចិត្តទុកដាក់ស្តាប់ខ្ញុំ។ បាទ!

កៈ អ៊ីចឹងសំនួរមួយនេះសម្រាប់ភាសាវិញ។

ខៈ តើអ្នកចេះអាន និង សរសេរភាសាខ្មែរបានល្អប៉ុន្មានដែរ? ចេះអានបាន តែសរសេរជួនកាលបានត្រូវជួនកាលខុសសរសេរបានខ្លះៗខុសខ្លះ។ បាទ! ដូចខ្ញុំបានប្រាប់អ្នកថាស្រុកកើតសង្គ្រាមខ្ញុំបានបាក់បែកក្នុងការសិក្សា។ បាទ! ពេលខ្ញុំធំខ្ញុំដើរឡើងប្រកបមុខរបរម៉ោង៥ឡើងខ្ញុំក្រោកបុកស្រូវជាមួយប្តី ខ្ញុំគ្មានម៉ាស៊ីនទេបុកដៃម៉ង អ៊ុំដៃចប់ ដើរទៅរកអុសរំងាស់ស្ករ។ បាទ! ក្នុងពេលនោះគ្រាប់សុទ្ធតែគ្រាប់មីននៅ ពេលដើរទៅរៀនទាល់តែជូនទៅបាន បានសុទ្ធតែគ្រាប់នៅកប់នឹងដីទាហានដើរទៅទាហានជូនទៅដល់ទីកន្លែងគ្រាប់កាប់គាស់ចុះបានដេញមកឆ្ងាយប្រៀបធៀបពីម៉ោង៥ដើរទៅពីហ្នឹងទៅគេហៅថាច្បារអំពៅទៅដល់ណោះដាំបាយដាក់ស្ពាយទៅហូបបាយទៅជីកអុសគាស់អុសជម្រៅត្រឹមៗនេះ គាស់ទម្រាំតែហើយរែកមក រែកឆ្ងាយពីហ្នឹងមកដល់ហ្នឹងបានដល់នៅតូចមិនធំទេអ្នក។ កាលហ្នឹងខ្ញុំនៅប្រហែលជាអាយុប្រហែលជា១១ឆ្នាំ។ បាទ! នៅតូចបាទខ្ញុំដុនដាបណាស់ ជីវភាពរបស់ខ្ញុំទាំងអស់បងប្អូនខ្ញុំ។ បាទ!

កៈ អ៊ីចឹងអ៊ុំមួយនេះទៀត ។

ខៈ អ្នកចេះនិយាយភាសាផ្សេងពីភាសាខ្មែរដែរអត់? អត់ចេះអ្នក។

កៈ អត់ចេះទេ?

ខៈ បាទ! អត់ចេះ ភាសាដូចជាបារាំងហ្នឹងតិចតួច និង ភាសាវៀតណាមតិចតួច មួយម៉ាត់ឬក៏ពីរម៉ាត់តែប៉ុណ្ណឹងទេ ហ្នឹងភាសាចិនតិចតួច។

កៈ ចាំស!

ខៈ ចេះដូចជាស្វាន ឬក៏អាំងកើម ដូចជា អើជាក់ពឹងអីអាហ្នឹងចេះ ចេះប៉ុណ្ណឹងទេ ។

កៈ អូខេអ៊ីចឹងនីយាយពីការសិក្សារបស់អ៊ុំ។

ខៈ តើអ្នករៀនបានកម្រិតថ្នាក់ទីប៉ុន្មាន? ទី៨ទំនើបដែរបាទ បាទ។

កៈ មួយនេះ។

ខៈ បាទ! បឋមសិក្សា មធ្យមសិក្សាបឋមភូមិឬមធ្យមសិក្សា។

កៈ មួយហ្នឹងអត់ត្រូវនិយាយពីសាលាអ៊ីវិញ តើសាលារៀនអ៊ុំនៅឯណា?

ខៈ តើសាលារបស់អ្នកនៅឯណា?នៅក្នុងខេត្តស្វាយរៀងអ្នក ភូមិដូនទង ឃុំធ្លក បាទៗ ឥឡូវសព្វថ្ងៃនេះខ្ញុំមិនគេហៅថាអ្វីទេ។

កៈ ចាំស! និយាយពីឈ្មោះសាលា។

ខៈ តើអ្នកចងចាំឈ្មោះរបស់សាលាដែរឬទេ? សាលាបាទចងចាំឈ្មោះរបស់សាលាគឺនៅក្នុងឃុំធ្លក សាលាដែលខ្ញុំរៀនហ្នឹងគឺនៅក្នុងឃុំធ្លកគឺនៅក្នុងស្រុក ភូមិដូនទង។

កៈ ឈ្មោះហាំអ៊ំឈ្មោះ។

ខៈ ឈ្មោះរបស់សាលាពីដើមគេហៅឈ្មោះថាសាលាធ្លក។ បាទ! សាលាសាលាធ្លក តែគេហៅឃុំធ្លកគេហៅថា គ្នាខ្ញុំទាំងអស់គ្នាម៉ែឪឱ្យហៅថាឱ្យវាទៅរៀនសាលាធ្លក ឈ្មោះសាលា។ តើអ្នកមានមិត្តភក្តិជិតស្និតដែលស្គាល់ដែលធំធាត់ជាមួយគ្នាដែរឬទេ?

កៈ មានទេអ៊ុំ?

ខៈ មាន តែបាក់បែកគ្នាអស់ហើយ បែកគ្នា ខ្លះគេធ្វើការរដ្ឋសព្វថ្ងៃនេះ ខ្លះធ្វើពេទ្យ ខ្លះធ្វើទាហាន ខ្លះធ្វើប៉ូលីស បែកបាក់គ្នាអស់ហើយទៅ បាទ ។

កៈ អូខេ! អ៊ីចឹងមួយនេះវិញ។

ខៈ សព្វថ្ងៃមាននៅមួយ នៅចំការមនធ្វើប៉ូលីសសក្តិ៥ អ្នករាប់អានគ្នាណាំ។ កូនប៉ុន្មាននាក់ឈ្មោះអីគេខ្លះ? កូនខ្ញុំសព្វថ្ងៃបាទ នៅ កូន៤នាក់តែស្លាប់មួយហើយនៅសល់៣នាក់ សព្វថ្ងៃនេះនៅក្នុងខេត្តបាត់ដំបងជិតពេទ្យ យាយជី។

ខៈ ឈ្មោះអ្វីខ្លះ?

ខៈ បាទ! ឈ្មោះអ្វីខ្លះ? បាទ! មួយឈ្មោះ យិន តូ បងមួយ ពីរឈ្មោះយិន តៃ បី យិន ហេង ប្អូនឈ្មោះយិន ទីន កូនស្រី ឥឡូវសព្វថ្ងៃនៅតែ៣ទេងាប់អស់១ហើយ។

កៈ ចាំស!

ខ៖ ស្លាប់ដោយសារគេបំពុលក៏មិនដឹងដែរគេមានប្រពន្ធនៅកំពង់ចាម។ បាទ! កូនខ្ញុំមិនដឹង ធ្វើអ្វីខុសក៏មិនដឹងតែគេធ្វើម្ហូបឱ្យហូប បកប្រែនៅថៃប៊ុនរ៉ុងសម្រាប់បងប្រែប្រទេសក្រៅមកអ្នក ហើយឥឡូវដល់រដ្ឋមានច្បាប់ទៅប្រពន្ធធ្វើម្ហូបឱ្យហូបស្រាប់តែពុលបែកពពុះមាត់ងាប់ភ្លាម ម៉ោង៩ ម៉ោង៥ទៅដល់ ម៉ោង៩ចាប់ហូបទាំងបងប្អូនខាងប្រពន្ធគេហូបគេអត់អីគេហូបខាងកូនខ្ញុំហូបពុលបែកពពុះមាត់ងាប់ម៉ង ហើយមូលហេតុគឺគេមានប្ដីទៀត។ បាទ! មូលហេតុហ្នឹងហើយខ្ញុំអត់ទាមទារអ្វីទេ មានសព្វថ្ងៃមានប្ដីទៀតកូនខ្ញុំស្លាប់បាន មួយឆ្នាំមានប្ដីបាទ។ តើអ៊ុំមានពាក្យពេចន៍អ្វីខ្លះដែលចង់ទូន្មានកូនក៏ដូចអប់រំកូន? ចិត្តគំនិតខ្ញុំគឺតែមួយក្រុមគ្រួសារខ្ញុំនឹងកូនរបស់ផងខ្ញុំបង្កើតៗអប់រំឱ្យដើរតាមផ្លូវល្អ
មិនឱ្យប្រហើនកោងកាចមិនឱ្យលួចប្លន់ឆក់បោកបញ្ឆោតគេទេ។ អ្នកនេះចិត្តគំនិតខ្ញុំសព្វថ្ងៃខំអប់រំកូនចៅក្នុងក្រុមគ្រួសារឱ្យបានស្អាតពីព្រោះខ្ញុំខំរៀនព្រះគម្ពីរខ្ញុំខំយកចិត្តទុកដាក់ទៅតាមរបស់ព្រះអំពើប្រហើនកោង កាច។ ខ្ញុំបោះបង់ចោលអស់ហើយ យកតម្រាប់នឹងបញ្ញត្តិរបស់ព្រះ ខ្ញុំអានព្រះគម្ពីរមេរមននេះ ចិត្តគំនិតខ្ញុំគឺទាំងអស់ទៅលើព្រះអស់ពីដួងចិត្តខ្ញុំហើយ។ បាទ! ខ្ញុំខំអប់រំកូនចៅ ឱ្យដើរតាមផ្លូវពិត។ បាទ! ខ្ញុំអស់ហើយអ្នកអត់មានអ្វី។

ក៖ ចាំស!

ខ៖ បើសិនជាអ្នកចង់ជួយអ្វីដល់ខ្ញុំមួយ ពីព្រោះខ្ញុំអត់មានប្រកបមុខរបរបានទេអ្នក បើអ្នកចង់ជួយសូមឱ្យគេជួយគេជួយម្ហូប អង្ករមួយខែៗ។ បាទ! ខ្ញុំយកមកដោះស្រាយក្នុងត្រកូលក្នុងរង្វង់ក្រុមគ្រួសារ។ បាទៗ! បើខ្ញុំប្រកបមុខរបរបាន បច្ចេកទេសប៉ុន្មានជាន់ខ្ញុំ ថៃ ប៊ុនរ៉ុង ខ្ញុំធ្វើឱ្យខាងសំណង់បាទ ខ្ញុំធ្វើបានថៃ ប៊ុន រ៉ុងទៅ ផុតពីថៃប៊ុនរ៉ុងទៅ ផ្ទះប្រជាពលរដ្ឋតាមរាស្ត្រស្រុកខ្មែរតូចៗ។ អីចឹងហាំ ខ្ញុំអត់ទទួលទេ ខ្ញុំទទួលផ្ទះស ខេង ផ្ទះហ៊ុន សែនផ្ទះលោកទា បាញ់ ផ្ទះធំៗណាស់ខ្ញុំធ្វើ ផ្ទះតូចៗអីចឹងខ្ញុំអត់ទទួលទេ បាទនេះគំរិះខ្ញុំបាទ។

ក៖ ចាំស!

ខ៖ ឥឡូវខ្ញុំធ្វើអត់កើតទេអ្នក ប៉ុន្តែបងប្អូនចង់ឱ្យយកខ្ញុំធ្វើឱ្យមានកម្មករឱ្យធ្វើបាន ខ្ញុំធ្វើអត់បានកាប់គាស់កាន់អត់បានអ្នកដើរក៏ដើរមិនចង់រួចដើរចង់ដួល ពោគធំណាស់។ សព្វថ្ងៃរស់ដោយសារថ្នាំ ព្រះលោកជួយខ្ញុំអស់ច្រើនណាស់ អស់៤០០០ដុល្លារហើយ ព្រះលោកជួយកុំអីខ្ញុំងាប់ហើយ។ ឥឡូវព្រះលោកឈប់ជួយចំនួន៦ខែមកហើយឈប់ហើយពេលដែលខ្ញុំឈឺធ្ងន់ចង់ងាប់ព្រះជួយអស់៤,០០០ដុល្លារ។ កុំអីខ្ញុំងាប់ហើយ ងាប់ហើយរស់មកវិញព្រះជួយខ្ញុំ។

កៈ ចាំស!

ខៈ ខ្ញុំមានអំណរយ៉ាងខ្លាំងយ៉ាងខ្លាំងទៅលើព្រះ ផុតពីសេចក្តីស្លាប់កុំអីខ្ញុំស្លាប់បាត់ទៅហើយ ក្នុងពេលនោះខ្ញុំអស់៤,០០០ដុល្លារ។ បាទ! អស់ហើយ។

កៈ អ៊ុំអរគុណច្រើនសម្រាប់ឱ្យខ្ញុំសម្ភាសអំពីជីវប្រវត្តិរបស់អ៊ុំ ។ ហើយដោយសារ អ៊ុំខ្ញុំសួរសំនួរ គាត់អីទាំងអស់អ៊ីចឹងមូលហេតុដែលខ្ញុំត្រូវអានឈ្មោះឪពុកម្តាយក៏ដូចជាឈ្មោះគាត់ដូចជា អ៊ុំត្រូវ គាត់បានតែអាន តែគាត់ស្តាប់សំនួរអ៊ីចឹងទេ អ៊ីចឹងដោយសារអ៊ុំមានជំងឺអ៊ីចឹងហាំ។ ហើយអ៊ីចឹងអ៊ុំហ្នឹងប្រាប់ពីមូលហេតុដែលអ៊ុំស្តាប់អត់ឮហាំ។

ខៈ មូលហេតុអីស្តាប់អត់ឮ? មូលហេតុខ្ញុំឈឺខ្លាំងអ្នកឈឺ ឈឺខ្លាំងខ្ញុំប្រើថ្នាំច្រើន ពេលដែល ខ្ញុំឈឺខ្លាំងនោះ គ្រូពេទ្យវះយកឆ្អឹងចេញឆ្អឹងហ្នឹងបាក់ ឆ្អឹងហ្នឹងបាក់ទាល់តែឥឡូវហ្នឹងវះយក ឆ្អឹងបែកឆ្អឹងហ្នឹងបែកតូចៗពីរបីចំណិតយកមកប្រាប់ខ្ញុំថាឆ្អឹងហ្នឹងហើយបែក ទៅផ្ទះចុះចាក់ ថ្នាំផ្សះ ដល់ផ្សះទៅស្រាប់តែម៉ោង៣រសៀល វាហឹងត្រចៀកខ្ញុំនិយាយ មនុស្សនិយាយ មិនឱ្យល្អមៗស្តាប់បាន ធ្លាក់ថ្ងៃបាត់ស្រមោលទៅ ខ្ញុំថ្លង់លែងឮ និយាយស្រែកយ៉ាងណាក៏អត់ឮដែរ
ហើយខ្ញុំនិយាយសម្លេងខ្លួនខ្ញុំសម្លេងខ្លួនខ្ញុំក៏ស្តាប់អត់ឮដែរ។ ខ្ញុំរត់ទៅពេទ្យត្រចៀក ពេទ្យ ត្រចៀករុកខ្សែក្រូមេតូចប៉ុនអំបោះរុក២ម៉ែត្រដកមកវិញសួរខ្ញុំសួរថាឮទេ? អត់ឮ បានគ្រូពេទ្យ ថារូបរាងកាយត្រចៀករបស់លោកពូនៅស្អាតទាំងអស់អត់ខូចអីទេ តែដោយសារលោកពូឈឺ ខ្លាំងប្រើថ្នាំច្រើនលើសកម្លាំងមនុស្សកែអត់បាន កែយ៉ាងម៉េចក៏មិនបាន សព្វថ្ងៃនេះ ពេទ្យ ព្រះយេស៊ូវលោកមើលខ្ញុំអត់យកលុយទេ នៅប្រចាំការនៅផ្សារមាន់អាំងសព្វថ្ងៃអ្នកមើលខ្ញុំ ម៉ាស៊ីនហ្នឹងប៉ុណ្ណឹងម៉ាស៊ីនដាក់នឹងហោរបៅអាវរួចទៅខ្សែដាក់ហ្នឹងត្រចៀកចុចកុងតាក់នឹងខោ បៅអាវហ្នឹងណាស់ ឮ ម៉ូតូពីណាមកបញ្ចេះ ឮតែស្តាប់អត់បានអ្នកស្តាប់មិនបានថាអំបិល ឬ ប្រហុកអ្នក គ្រាន់តែអីស្តាប់អត់បានទេ គ្រាន់តែឮៗ ខ្ញុំនិយាយដោយខ្លួនខ្ញុំស្តាប់ឮ តែមិនដឹង ថាសម្លេងយ៉ាងម៉េច ។

កៈ អ៊ីចឹងគាត់ប្រាប់ពីមូលហេតុ។

ខៈ អ៊ីចឹងព្រះសួរថាចុះបើឮហើយស្តាប់មិនបានរបស់ហ្នឹងចង់បានទេ? ចង់បានឱ្យ តម្លៃ ២,៥០០ដុល្លារធ្វើសំបុត្រឱ្យថ្មបើអស់ថ្មយកសំបុត្រហ្នឹងមកបើកថ្ម។ ខ្ញុំនិយាយជម្រាបទៅ វិញ ថាខ្ញុំអត់ចង់បាន បើខ្ញុំចង់បានរបស់នេះទាល់តែឮ ហើយឱ្យខ្ញុំស្តាប់បានថា ម៉ូតូ ឬក៏ អំបិល

ប្រហុកអីបានខ្ញុំយក។ ឥឡូវស្តាប់ឮហើយស្តាប់មិនបានខ្ញុំអត់យកខ្ញុំអត់ហ៊ានចិត្តក្បត់នឹងព្រះទេ មិនហ៊ានយក បើហ៊ានយក២,០០០ជាងម៉ាស៊ីនហ្នឹង បើប្រើថ្មអស់ឱ្យយកសំបុត្រមកបើកថ្មខ្ញុំអត់យកខ្ញុំមិនយកទេ។

ក៖ ចាំស!

ខ៖ គេត្រចៀកមនុស្សនិយាយខ្លាំងណាស់ ស្តាប់បាននិយាយបានឆ្លើយឆ្លងទាំងអស់និយាយខ្លាំងក៏ឮម៉ាស៊ីនហ្នឹង។បើខ្ញុំ
ខ្ញុំឮថាស្តាប់មិនបានបើខ្ញុំចិត្តក្បត់ខ្ញុំយកម៉ាស៊ីនហ្នឹងមកលក់ហើយឱ្យពួកដែលត្រចៀកធ្ងន់ហ្នឹងហាំ។ គេស្តាប់បានខ្ញុំអត់ហ៊ានយក។

ក៖ ដោយសារអ៊ុំមានចិត្តស្មោះនឹងព្រះ។ អញ្ចឹងថ្ងៃហ្នឹងការសម្ភាសអ៊ុំគឺមានតែប៉ុណ្ណឹង ហើយអ្វីទាំងអស់គឺកូនចៅរបស់អ៊ុំបានស្តាប់ពីប្រវត្តិខ្លះៗ ដោយសារសំនួរខ្លះ។ គាត់អត់ស្វរយល់ហើយអ្វីដែលសំខាន់គឺគាត់ថាគាត់បានសិក្សាតែបន្តិចហើយឥឡូវសភាពចាស់ទៅក៏អ៊ុំអត់ស្វរបានស្តាប់បានច្រើនតែថ្ងៃហ្នឹងអរគុណច្រើនមែនទែន។អ៊ុំអរគុណសម្រាប់ការសម្ភាសសុខសប្បាយណាំអ៊ុំ។

ខ៖ អរគុណអ្នកបានជួយណែនាំនឹងអស់បារម្ភខ្ញុំមានអំណរយ៉ាងខ្លាំង។

ក៖ ចាំសៗអរគុណអ៊ុំ។